# របាយការណ៍រួមស្តីពីយោបល់ និងអនុសាសន៍ចំពោះ
# សេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១១

រៀបចំ ដោយ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

## ១. វិសាលភាពនៃការពិនិត្យ

១.១ វិសាលភាពនៃការពិនិត្យនេះមានមូលដ្ឋានលើសេចក្តីព្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែន រដ្ឋាភិបាល (សេចក្តីព្រាងច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល) ដែលផ្សព្វផ្សាយដោយក្រសួងមហាផ្ទៃចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១០ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ ច្បាប់ការងារកម្ពុជា ក្រមរដ្ឋប្បវេណីកម្ពុជា ព្រមទាំង លិខិតូបករណ៍ អន្តរជាតិដូចជាសេចក្តីថ្លែការជាសាកលស្តីអំពីសិទ្ធិមនុស្ស អនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និង អនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌[i] ។

២.២ ការពិនិត្យនេះផ្អែកលើការវិភាគលើសេចក្តីព្រាងច្បាប់អង្គការមិនមែនរដ្ឋាភិបាលដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលកំពុងប្រតិបត្តិការនៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល អន្តរជាតិដែល ធ្វើប្រតិបត្តិការនៅក្រៅប្រទេស សមាគមជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ដូចជា អង្គការ **CDP** អង្គការ **LICADHO** អង្គការ **CLEC** អង្គការ **EWMI** អង្គការ **ICNL** អង្គការ FS និងដៃគូរបស់ខ្លួន **(FSP)** អង្គការ **GADC** អង្គការមិនមែរដ្ឋាភិបាលជប៉ុន **(JNGOs)**[ii] របាយការណ៍របស់ក្រុមការងារ ពិគ្រោះយោបល់នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១០ **(WG)** អង្គការ **CCHR.** អង្គការ **MEDiCAM** អង្គការ NGO Forum, អង្គការ **Star Kampuchea** អង្គការ **NEP** និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលនៅបាត់ដំបង ស្វាយរៀង និង សៀមរាប ។

## ២. របាយការណ៍សង្ខេប

### ២.១ បរិបទជាតិ

សេចក្តី ច្បាប់អង្គការមិនមែន រដ្ឋាភិបាលគឺជាសកម្មភាពមួយក្នុងចំណោម សកម្មភាព ទាំង ឡាយ (សកម្មភាព ១.៤.១) នៃយុទ្ធសាស្ត្រទី ១ " ការការពារ សេរីភាពបុគ្គល" នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង តុលាការកម្ពុជា[iii] ។ យុទ្ធសាស្ត្រនេះដកស្រង់ចេញ ពីគោលការណ៍ជាមូលដ្ឋានចំនួន ៤ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ កម្ពុជា:

១. សិទ្ធិសេរីភាពបុគ្គល

២. ប្រជាធិបតេយ្យសេរី

៣. ការបែងចែងអំណាច

៤. នីតិរដ្ឋ

សិទ្ធិរបស់បុគ្គលតាមតាមគោលការណ៍ទី១ បានកំណត់ថា

ការរឹតត្បិតសេរីភាព និងសិទ្ធរបស់បុគ្គលដោយ ដោយអំណាចណាមួយអាចធ្វើទៅបាន ដរាបណាតែស្របច្បាប់ ហើយត្រូវចាត់ទុកជាការចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ។ នៅការជ្រៀតជ្រែកណាមួយចំពោះ សេរីភាពនិង សិទ្ធិរបស់បុគ្គល អង្គការគ្រប់គ្រងរដ្ឋនានាត្រូវប្រកាន់ឱ្យបានតឹងរឹងនូវគោលកាណ៍ដែលកំណត់ថា ការជ្រៀតជ្រែក នោះត្រូវតែសមាមាត្រទៅនឹងគោលបំណងដែលប្រាថ្នាចង់បាន[iv]។

យើងកត់សំគាល់ឃើញផងដែរថា រដ្ឋធម្មនុញ្ញកម្ពុជាក៏បានទទួលស្គាល់នឹងគោរពសិទ្ធិមនុស្សដែលមានចែងក្នុង ធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីថ្លែងការជាសាកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញានិង អនុសញ្ញា ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ (មាត្រា ៣១) ព្រមទាំងចែងអំពីសេរីភាពក្នុងការបង្កើតសមាគម (មាត្រា ៤២)។

មាត្រា ២ នៃសេចក្តីព្រាងច្បាប់នេះឆ្លើយតបនឹងគោលគំនិតនេះដោយចែងអំពីគោលបំណងនៃច្បាប់នេះថា "ដើម្បី លើកកម្ពស់ការអនុវត្តសិទ្ធិសេរីភាព របស់ ប្រជាពលរដ្ឋខ្មែរ ក្នុងការបង្កើតសមាគម អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក ដើម្បីរួម គ្នាការពារផលប្រយោជន៏ស្របច្បាប់របស់ខ្លួន និងផលប្រយោជន៏សាធារណៈ"។ ទោះបីជាយ៉ាង នេះក៏ដោយ ការស្ទង់មតិលើអង្គការចំនួន...ដែលវិភាគលើសេចក្តីព្រាងច្បាប់ បានបង្ហាញអំពីការព្រួយបារម្ភលើការ អនុវត្តសិទ្ធិ និងសេរីភាពដែលផ្តល់ដោយរដ្ឋធម្មនុញ្ញ និងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ ដែលបាន រៀបរាប់ខាងលើ។ សេចក្តីសង្ខេបនៃការព្រួយបារម្ភ និងអនុសាសន៏របស់ពួកគេត្រូវបានបង្ហាញក្នុងតារាង នៃផ្នែកទី ៤ខាងក្រោមដែលមានចំណងជើងថា ៤. មតិរួមរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការ មិនមែន រដ្ឋាភិបាលក្នុងស្រុកចំពោះសេចក្តីព្រាងច្បាប់ស្តីអំពីអង្គការមិនមែនរដ្ឋាភិបាល។

## ២.២ សេចក្តីសង្ខេបចម្លើយឆ្លើយតបអំពីបញ្ហា និងអនុសាសន៏របស់អង្គការមិនមែនរដ្ឋាភិបាល

អង្គការសង្គមស៊ីវិលយល់ដឹងពីភាពចាំបាច់របស់រដ្ឋាភិបាលដើម្បីបង្កើតក្របខណ្ឌច្បាប់មួយដើម្បីធានានូវស្ថិរភាព និង សន្តិសុខរបស់សង្គមព្រមទាំងដើម្បីធានាឱ្យជំនួយ ដល់ការអភិវឌ្ឍន៏ និងមនុស្សធម៌បានអនុវត្តទៅដោយមាន ប្រសិទ្ធិ ភាព។ ប៉ុន្តែ សេចក្តីត្រូវការនៃក្របខណ្ឌច្បាប់នោះ ត្រូវធានានូវសិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋ ក្នុងការចូល រួមក្នុង សកម្មភាពស្រប ច្បាប់ដោយគ្មានការរិតត្បិត ឬការដាក់បន្ទុក។

មាត្រា ២នៃសេចក្តីព្រាងច្បាប់អង្គការមិនមែនរដ្ឋាភិបាលចែងអំពីនីតិវិធីនៃការចុះបញ្ជីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ នៅខណៈពេលដែលសិទ្ធិទទួលបាននីតិបុគ្គលត្រូវបានកំណត់នៅក្នុងជំពូកនេះ " ការប្រើប្រព័ន្ធចុះបញ្ជីត្រូវ ធានាថា វាពិតជាងាយស្រួល ដែលមាននីតិវិធីច្បាស់លាស់ ឆាប់រហ័ស មិនមានលក្ខណៈនយោបាយ និងមិនថ្លៃពេក" [v] ។ទោះបីជាយ៉ាងនេះក៏ដោយលក្ខខណ្ឌនៃការចុះបញ្ជីក្នុងមាត្រានេះមានលក្ខណៈលើសលប់ (ឧ ឯកសារ និងសមាជិកភាព)និងដាក់បន្ទុកហួសហេតុដលអង្គការដែលមានបំណងធ្វើប្រតិបត្តិការដោយស្របច្បាប់នៅកម្ពុជា។ បន្ថែមពីនេះ លក្ខខណ្ឌនៃការចុះបញ្ជីលើសពីលក្ខខណ្ឌដែលមានចែងក្នុងក្រមរដ្ឋប្បវេណី (មាត្រា៥០)។ សេចក្តីព្រាងច្បាប់អង្គការមិនមែនរដ្ឋាភិបាល មានការខ្វះខាតអំពីដំណើរការច្បាប់លាស់ និងតម្លាភាពសម្រាប់ ការវាយតម្លៃ និងការបដិសេធនូវពាក្យសុំចុះបញ្ជី ឬ ឱកាសនៃការប្តឹងឧទ្ធរណ៍ទៅសាលា ជម្រះក្តីដែលឯករាជ និងមានភាពមិនលំអៀង។

មាត្រា ៤៩ នៃជំពូកទី ៨ ចែងអំពីការផ្អាកសកម្មភាព និងការរំលាយអង្គការមិនមែនរដ្ឋាភិបាលនិងសមាគមក្នុងស្រុកដោយស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្ត ចំណែកឯ មាត្រា ៥០ ចែងអំពីការ ផ្អាកសកម្មភាព ឬការបញ្ចប់សុពលភាពនៃអនុស្សារណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ដោយស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្ត។ មាត្រានេះមានការខ្វះខាតពីគោលការណ៍ច្បាស់លាស់ និងសង្ខេបអំពីការកំណត់របស់រដ្ឋាភិបាលអំពីការផ្អាក ឬការបញ្ចប់ដោយមិនស្ម័គ្រចិត្ត។មាត្រានេះក៏មិនបានចែងអំពីលក្ខខណ្ឌដែលរដ្ឋាភិបាលត្រូវធ្វើការជូនដំណឹងដល់អង្គការដែលប្រឈមនឹងការផ្អាក ឬការបញ្ចប់ដោយមិនស្ម័គ្រចិត្តដែរ។ សេចក្តីជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យច្បាស់អំពីឱកាសនៃការប្តឹងឧទ្ធរណ៍អំពីការផ្អាក ឬការបញ្ចប់ដោយ មិនស្ម័គ្រចិត្ត ឬទាំងពីរ នៅមុននិងក្រោយអំពើនេះដែរ។

មាត្រា ៥២ ចែងថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលត្រូវបានរំលាយ ការចាត់ចែងធនធាន និងទ្រព្យ សម្បត្តិត្រូវអនុវត្តតាមសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ ដោយមិនបានភ្ជាប់លក្ខខណ្ឌដែលតុលាការត្រូវយោងលើ លក្ខន្តិកៈរបស់អង្គការ អនុស្សារណៈ ឬកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ។__

សេចក្តីព្រាងច្បាប់អង្គការមិនមែនរដ្ឋាភិបាលចែងអំពីកាតព្វកិច្ចនៃការរាយការណ៍អំពីសកម្មភាព ស្ថានភាពនៃថវិកា និងផែនការសកម្មភាព។ ប្រព័ន្ធនៃការរាយការណ៍គឺមានសារៈសំខាន់ណាស់សម្រាប់ឱ្យអង្គការសង្គមស៊ីវិលដ៏ល្អមួយ

ប៉ុន្តែបញ្ញត្តិនៃការតាមដាននិងត្រួតពិនិត្យ មិនត្រូវមានការលំបាកដែលធ្វើឱ្យរាំងស្ទះដល់សកម្មភាពរបស់អង្គការដែលគ្រប់គ្រងដោយច្បាប់នោះទេ។លក្ខខណ្ឌនៃការរាយការណ៍ដែលមានចែងក្នុងមាត្រា ៤៤ មាត្រា ៤៦ និង មាត្រា ៤៨ នឹងដាក់បន្ទុកដល់អង្គការមហាជនតូចៗនៅតាមសហគមន៍ នៅតាមខេត្ត ក្រុង និងសម្ព័ន្ធនៃអង្គការដែលមិន អាចធ្វើរបាយការណ៍បាន។ ហេតុនេះហើយការបង្កើតប្រព័ន្ធឱ្យសាមញ្ញវានឹងផ្តល់ផល ប្រយោជន៍ដល់ការ កាត់បន្ថយបន្ទុករដ្ឋបាល ដល់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមហាជននៅតាម សហគមន៍ ខេត្តក្រុងដែលមានលក្ខណៈតូចតាចដែលអាចនិយាយថាជាភ្នាក់សំខាន់សម្រាប់ ការអភិវឌ្ឍន៍ដែលមានចិរភាពនៅកម្ពុជា។

បញ្ហាកង្វល់ចុងក្រោយគឺ សេចក្តីព្រាងច្បាប់អង្គការមិនមែនរដ្ឋាភិបាលនេះមានពាក្យពេចន៍ និងឃ្លាដែលមាន ន័យមិនច្បាស់លាស់សម្រាប់អ្នកអនុវត្តច្បាប់។ ហេតុនេះហើយអ្នកអាចបកស្រាយបានច្រើនយ៉ាង។

អង្គការមិនមែនរដ្ឋាភិបាលបរទេស និងដៃគូរអភិវឌ្ឍន៍បាននាំមកនូវធនធាន និងចំណេះដឹងជាច្រើនដល់ព្រះរាជាណាចក្រកម្ពុជា។ ផ្អែកតាមខ្លឹមសារនៃសេចក្តីព្រាងច្បាប់បច្ចុប្បន្ន វានឹងធ្វើការរឹតត្បិតដល់ការងារដល់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះពីព្រោះវាបង្កើតជាឧបសគ្គចំបងចំពោះការចុះបញ្ជី និងការអនុវត្តសកម្មភាពរបស់ពួកគេ។ ផលវិបាកដែលកើតចេញពីច្បាប់នេះគឺការថយចុះនូវមូលនិធិសម្រាប់ការអភិវឌ្ឍន៍គម្រោងសំខាន់ៗជាច្រើនដែលកំពុងសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៅពេលបច្ចុប្បន្ន និងប្រភពមូលនិធិ ថ្មីទៀតសម្រាប់ការអភិវឌ្ឍន៍រយៈពេលវែង។

បន្ថែមពីលើផលប៉ះពាល់ដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ច្បាប់នេះនឹងប៉ះពាល់ដល់កម្មវិធីរបស់រដ្ឋាភិបាលផងដែរ។អត្ថន័យមិនច្បាស់លាស់ព្រមទាំងលក្ខខណ្ឌនៃការចុះបញ្ជីនិង របាយការណ៍ដែលមាន ភាពស្មុគ្រស្មាញ នឹងដាក់បន្ទុកទៅលើភ្នាក់ងាររបស់រដ្ឋាភិបាលដែលអនុវត្តច្បាប់ ថ្មីនេះ ជាពិសេសក្រសួងមហា ផ្ទៃ និង ក្រសួងការបរទេស និងទំនាក់ទំនងអន្តរជាតិ។ វានឹងមាន ប្រយោជន៍ដល់រដ្ឋាភិបាលប្រសិនបើ ពាក្យពេចន៍ទាំអស់ត្រូវបានចែងឱ្យច្បាស់ និងធ្វើឱ្យដំណើរការចុះបញ្ជី និងរបាយការណ៍ មានលក្ខណៈសាមញ្ញ។ ហេតុនេះហើយអង្គការសង្គមស៊ីវិលស្នើសុំឱ្យមាន ការពិគ្រោះ យោបល់ បន្ថែមបន្ទាប់ពីការពិគ្រោះយោបល់ថ្នាក់ជាតិនៅថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១១។

## ៣. មតិរួមរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំពោះសេចក្តីព្រាងច្បាប់ស្តីអំពីអង្គការមិនមែនរដ្ឋាភិបាល

| **អត្ថបទដើម** | **អនុសាសន៍** |
|---|---|
| **មាត្រា៦.-បញ្ញត្តិហាមឃាត់**<br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុង ស្រុកដែលមិនបានចុះបញ្ជី ឬចុះអនុស្សរណៈស្របតាម ច្បាប់នេះមិនត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ | - សិទ្ធិនៃការចុះបញ្ជីគួរតែជាសិទ្ធិ របស់បុគ្គល ឬ ក្រុម។ ការចុះបញ្ជីនឹងផ្តល់ឱ្យអង្គការនូវឋានៈជាអង្គការមិនរកប្រាក់ចំណេញដែលអនុញ្ញាតឱ្យអង្គការនោះទទួលបាននូវផលប្រយោជន៍ដូចជាការកាត់បន្ថយពន្ធដារ និងការការពារខុសគ្នា តាមច្បាប់។<br>-អង្គការដែលបានចុះបញ្ជីហើយនៅពេលបច្ចុប្បន្នហើយបានដាក់ពាក្យចុះបញ្ជីឡើងវិញគួរទទួលបានការអនុញ្ញាតឱ្យធ្វើសកម្មភាពជាបណ្តោះអាសន្ន ។ការធ្វើសកម្មភាពនេះត្រូវបដិសេធប្រសិនបើការសុំចុះបញ្ជីឡើងវិញត្រូវបដិសេធដោយក្រសួងមហាផ្ទៃ។ |
| **មាត្រា៨.-ល័ក្ខខណ្ឌនៃការបង្កើតសមាគម**<br>ដើម្បីបង្កើតសមាគមបាន ត្រូវមានសមាជិកស្ថាបនិក ដែលមានសញ្ជាតិខ្មែរចំនួនពីម្ភៃមួយ (២១)នាក់ឡើង ទៅ។<br>សមាជិកទាំងនេះ ត្រូវធ្វើការជ្រើសរើសថ្នាក់ដឹកនាំ សមាគមយ៉ាងតិច (០៧) នាក់សម្រាប់រៀបចំ បែបបទ និងបំពេញល័ក្ខខណ្ឌស្នើសុំចុះបញ្ជី។ | -បន្ថយចំនួនសមាជិកនិង ថ្នាក់ដឹកនាំ។។<br>-កែមាត្រានេះដោយលុបបំបាត់ចោលនូវលក្ខខណ្ឌ សញ្ជាតិសម្រាប់សមាជិកស្ថានិក ហើយធានាថា ជនគ្រប់រូប (ឧ បុគ្គលនៅក្នុងដែនដីរបស់រដ្ឋទាំងអស់ ដែលស្ថិត នៅក្រោមយុត្តាធិការរបស់រដ្ឋ) មានសិទ្ធិបង្កើត សមាគម។ |
| **មាត្រា ៩.- ល័ក្ខខណ្ឌនៃការបង្កើតអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក**<br>ដើម្បីបង្កើតអង្គការមិនមែនរដ្ឋាភិបាលក្នុង ស្រុកបាន ត្រូវមានអ្នកផ្តួចផ្តើមដែលមានសញ្ជាតិខ្មែរ យ៉ាងហោចណាស់ (០៣) នាក់ឡើងទៅ។ | -កែមាត្រានេះដោយលុបបំបាត់ចោលនូវលក្ខខណ្ឌ សញ្ជាតិសម្រាប់សមាជិកស្ថានិក ហើយធានាថា ជនគ្រប់រូប (ឧ បុគ្គលនៅក្នុងដែនដី |

| | |
|---|---|
| សមាជិកទាំងនេះ ត្រូវធ្វើការជ្រើសរើស ប្រធានមួយរូប សម្រាប់រៀបចំបែបបទ និងបំពេញល័ក្ខខណ្ឌ ស្នើសុំចុះបញ្ជី។ | របស់រដ្ឋទាំងអស់ ដែលស្ថិត នៅក្រោមយុត្តាធិការ របស់រដ្ឋ) មានសិទ្ធិបង្កើត សមាគម។ |
| **មាត្រា១០.-លក្ខន្តិកៈរបស់សមាគម ឬអង្គការមិន មែនរដ្ឋាភិបាលក្នុងស្រុក**<br>ថ្នាក់ដឹកនាំរបស់សមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក ត្រូវរៀបចំលក្ខន្តិកៈរបស់ខ្លួន។<br>លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុកត្រូវគោរពតាមរដ្ឋធម្មនុញ្ញ និង ច្បាប់នានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។<br>លក្ខន្តិកៈរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវមានចែង ចំណុចសំខាន់ៗ ដូច ខាងក្រោមៈ<br>- ឈ្មោះជាអក្សរពេញ អក្សរកាត់ និងសញ្ញា សម្គាល់<br>- គោលបំណង និងទិសដៅ<br>- វិធានការជ្រើសរើស ការបញ្ឈប់ ការបណ្តេញ ចេញ ការផ្លាស់ប្តូរ ការដកហូតតំណែង សមាជិក បុគ្គលិក ប្រធាន និងថ្នាក់ដឹកនាំ<br>- សិទ្ធិ និងភារកិច្ចរបស់សមាជិក ឬបុគ្គលិក<br>- រចនាសម្ព័ន្ធ អាណត្តិ តួនាទី ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅនៃ អង្គការដឹកនាំនានា<br>- អង្គការដឹកនាំនានា រួមមាន សន្និបាត ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនាយក គណៈកម្មាធិការប្រតិបត្តិ ឬអង្គការសមមូល<br>- វិធានការប្រជុំសាមញ្ញ និងវិសាមញ្ញនៃអង្គការ ដឹកនាំនានា | -កែមាត្រានេះឱ្យមានភាពសមញ្ញដើម្បីឱ្យស្របជា មួយ ក្រមរដ្ឋប្បវេណី |

| | |
|---|---|
| - ប្រភពធនធាន និងទ្រព្យសម្បត្តិ<br>- វិធានការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ<br>- វិធានការប្តូរឈ្មោះ ការប្តូរសញ្ញាសម្គាល់ ឬការ ធ្វើវិសោធនកម្មលក្ខន្តិកៈ<br>- វិធានការនៃការរំលាយ និងការចាត់ចែង ធនធាន និងទ្រព្យសម្បត្តិ នៅពេលត្រូវបាន រំលាយខ្លួន។ | |
| **មាត្រា១៤.- សំណុំលិខិតសុំចុះបញ្ជីសមាគម**<br>ប្រធានសមាគមត្រូវដាក់ពាក្យសុំចុះបញ្ជីនៅក្រសួង មហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូច ខាងក្រោម :<br>- ពាក្យសុំចុះបញ្ជី ដោយប្រធានសមាគម ពីរ (០២) ច្បាប់<br>- តារាងបញ្ជីឈ្មោះស្ថាបនិកចំនួនចាប់ពីម្ភៃមួយ (២១) នាក់ ឡើងទៅដោយមានបញ្ជាក់អំពី អាយុ ភេទ សញ្ជាតិ អាសយដ្ឋានអចិន្ត្រៃយ៍។ សមាជិកទាំងនេះត្រូវធ្វើការជ្រើសរើសថ្នាក់ដឹកនាំសមាគមយ៉ាងតិចចំនួនប្រាំពីរ (០៧) នាក់ សម្រាប់រៀបចំបែបបទ និងបំពេញល័ក្ខខណ្ឌ ស្នើសុំចុះបញ្ជី<br>- លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការ កណ្តាលរបស់សមាគម ដោយមានការទទួលស្គាល់ពីមេឃុំ ឬចៅសង្កាត់មួយ (០១) ច្បាប់<br>- លក្ខន្តិកៈចុះហត្ថលេខាដោយប្រធាន និងថ្នាក់ ដឹកនាំសមាគមទាំងអស់ពីរ (០២) ច្បាប់ | -កែមាត្រានេះឱ្យមានភាពសមញ្ញដើម្បីឱ្យស្របជា មួយ ក្រមរដ្ឋប្បវេណី<br>-បញ្ជាក់ឱ្យច្បាសឱ្យនូវលក្ខខណ្ឌនៃ ការផ្តល់ " ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំ" ។ |

| | |
|---|---|
| - ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំសមាគម យ៉ាងតិចចំនួនប្រាំពីរ (០៧) នាក់ក្នុងម្នាក់ពីរ (០២) ច្បាប់ ដោយមានបិទរូបថតបច្ចុប្បន្នទំហំ ៤ គុណនឹង ៦<br>- បង្កាន់ដៃថ្លៃអាករចុះបញ្ជីសមាគមមួយ (០១) ច្បាប់ | |
| **មាត្រា១៥.-សុំណុំលិខិតសុំចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**<br>ប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវដាក់ពាក្យសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដោយ ភ្ជាប់មកជាមួយនូវសុំណុំលិខិតដូចខាងក្រោម:<br>- ពាក្យសុំចុះបញ្ជី ដោយប្រធានអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុកពីរ (០២) ច្បាប់<br>- លិខិតបញ្ជាក់អាស័យដ្ឋានទីស្នាក់ការកណ្តាល របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដោយមានការទទួលស្គាល់ពីមេឃុំ ឬចៅ សង្កាត់មួយ (០១) ច្បាប់<br>- លក្ខន្តិកៈចុះហត្ថលេខា ដោយប្រធានអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុកពីរ(០២)ច្បាប់<br>- ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកយ៉ាងតិចបី (០៣) នាក់ ក្នុងម្នាក់ពីរ (០២) ច្បាប់ដោយមានបិទរូបថត បច្ចុប្បន្នទំហំ ៤ គុណនឹង ៦<br>- បង្កាន់ដៃថ្លូអាករចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ (០១) ច្បាប់<br>- លិខិតប្រកាសគណនីធនាគារដែលបានផ្ញើរនៅធនាគារណាមួយ ដែលទទួលស្គាល់ដោយ ធនាគារជាតិនៃកម្ពុជាមួយ (០១) ច្បាប់ ។ | អនុសាសន៍ដូចមាត្រា ១៤ដែរ |
| **មាត្រា១៧.-ការពិនិត្យសំណុំលិខិត និងការឆ្លើយតប** | -បន្ថែមនិងកំណត់ពីមូលហេតុនៃការបដិសេធឱ្យឧបានច្បាស់លាស់ ។ |

| | |
|---|---|
| ក្រសួងមហាផ្ទៃត្រូវពិនិត្យសំណុំលិខិត និងនីត្យានុកូល ភាពនៃលក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក ហើយត្រូវសម្រេចយល់ព្រម ចុះបញ្ជី ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ (៤៥) ថ្ងៃ នៃថ្ងៃធ្វើការ។ | -បន្ថែមប្រសិនបើ ក្រសួង មហាផ្ទៃ មិន"បានឆ្លើយតបតាមកាលកំណត់ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះចាត់ទុកថាបាន ចុះបញ្ជី។ |
| **មាត្រា១៨.-ការកែតម្រូវខ្លឹមសារ និងការឆ្លើយតប**<br>ក្រសួងមហាផ្ទៃ ត្រូវធ្វើលិខិតជូនដំណឹងជាលាយ លក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ទៅសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកណាដែលបំពេញបែបបទដែលមានខ្លឹមសារ មិនទាន់សមស្របតាមរដ្ឋធម្មនុញ្ញ ឬច្បាប់ជាធរមាន និងស្នើសុំឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ (៤៥) ថ្ងៃ។<br>ក្នុងករណីពិនិត្យឃើញថាសមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុកបានកែតម្រូវខ្លឹមសារសមស្រប ឬ ចំណុចខ្វះខាតរួចហើយក្រសួងមហាផ្ទៃ ត្រូវចុះបញ្ជី ក្នុងរយៈពេលយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតកែតម្រូវ។ | -បញ្ជាក់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការពិនិត្យពាក្យសុំឱ្យបានច្បាស់លាស់<br>-ផ្តល់សិទ្ធិសម្រាប់ការប្តឹងឧទ្ធរណ៍ចំពោះការបដិសេធពាក្យសុំចុះបញ្ជី |
| **មាត្រា២១.-លក្ខខណ្ឌនៃការបង្កើតសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**<br>ដើម្បីបង្កើតសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋា ភិបាលក្នុងស្រុកបានត្រូវមាន សមាជិកស្ថាបនិក ដែល ជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលស្របច្បាប់យ៉ាងហោចណាស់ពីរ (០២) ឡើង ទៅ។<br>សមាជិកទាំងនេះត្រូវធ្វើការជ្រើសរើសប្រធានសម្ព័ន្ធមួយរូបសម្រាប់រៀបចំបែបបទ និងបំពេញល័ក្ខខ័ណ្ឌស្នើ សុំចុះបញ្ជី។ | - បញ្ជាក់ឱ្យច្បាស់ថាសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋា ភិបាលក្នុងស្រុក ដែលបង្កើតឡើងដោយសមាគមឬអង្កការមិនមែន រដ្ឋាភិបាលចំនួន២ មិនតម្រូវឱ្យចុះបញ្ជី។<br>-កែសម្រួលបញ្ញត្តិនេះដើម្បីឱ្យអង្គការអន្តរជាតិអាចចងសម្ព័ន្ធជាមួយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក |
| **មាត្រា ២៣.-សំណុំលិខិតសុំចុះបញ្ជីសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**<br>ប្រធានសម្ព័ន្ធសមាគម ឬអង្គការមិនរដ្ឋាភិបាលក្នុង ស្រុក | -ការចុះបញ្ជីសម្ព័ន្ធសមាគម ឬអង្គការត្រូវធ្វើដោយស្ម័គ្រចិត្ត ពីព្រោះ |

| | |
|---|---|
| ត្រូវដាក់ពាក្យសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ<br>ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម:<br>- ពាក្យសុំចុះបញ្ជី ដោយប្រធានរបស់សម្ព័ន្ធ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួនពីរ (០២) ច្បាប់<br>- សេចក្តីសម្រេចចុះបញ្ជីរបស់សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលជាសមាជិកសម្ព័ន្ធមួយ (០១) ច្បាប់<br>- លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកដោយមានការទទួលស្គាល់ ពីមេឃុំ ឬចៅសង្កាត់មួយ (០១) ច្បាប់<br>- លក្ខន្តិកៈរួមចុះហត្ថលេខាដោយប្រធានសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីរ (០២) ច្បាប់<br>- ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកម្នាក់ ពីរ (០២) ច្បាប់ ដោយមានបិទរូបថតបច្ចុប្បន្ន ទំហំ ៤ គុណនឹង ៦<br>- បង្កាន់ដៃថ្លៃអាករចុះបញ្ជីរបស់សម្ព័ន្ធសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ (០១) ច្បាប់<br>- លិខិប្រកាសគណនីធនាគារដែលបានផ្ញើនៅធនាគារណាមួយដែលទទួលស្គាល់ដោយធនាគារ ជាតិនៃកម្ពុជាមួយ (០១) ច្បាប់ ។ | សមាជិកអង្គការបានបំពេញ កាតព្វកិច្ចចុះបញ្ជីរួចហើយ ។<br>- អនុសាសន៍ដូចគ្នានឹងមាត្រា ១០-១៥<br>. |

| | |
|---|---|
| **មាត្រា២៧.-កិច្ចសហការរវាងសមាគមជាមួយអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុក**<br>សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុង ស្រុកដែលស្របច្បាប់ អាចធ្វើកិច្ចសហការជាមួយគ្នាបាន ដើម្បីអនុវត្តគម្រោងណាមួយស្របច្បាប់តាម សេចក្តីសម្រេចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដោយ គ្រាន់តែជូនដំណឹងជាលាយ លក្ខណ៍អក្សរមកក្រសួងមហាផ្ទៃ និងភ្ជាប់មកជាមួយ នូវ :<br>-កិច្ចព្រមព្រៀង ឬឯកសារសមមូល ឬល័ក្ខខ័ណ្ឌនានា នៃកិច្ចសហការ<br>-ចំនួន និង ឈ្មោះសមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុកដែលបានចូលរួម។ | - ចែងឱ្យច្បាស់ថា សមាគមនិងអង្គការមិន មែនរដ្ឋាភិបាលដែលមិនចង់ចងសម្ព័ន្ធនៅតែអាចធ្វើការ ជាមួយគ្នាចំពោះបញ្ហារួម។<br>-លុបចោលនូវ លក្ខខណ្ឌដែលត្រូវជូនដំណឹងទៅក្រសួង មហា ផ្ទៃនៅពេលដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល សហការគ្នា។<br>-បញ្ជាក់ឱ្យច្បាស់ថាតើកាលៈទេសៈណាដែលសម្ព័ន្ធអង្គការឬសមាគមត្រូវជូនដំណឹងអំពីគម្រោង។ |
| **មាត្រា៣០.- សំណុំលិខិតសុំចុះអនុស្សរណៈរបស់ អង្គការមិនមែនរដ្ឋាភិបាលបរទេស**<br>អង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងអនុវត្តគម្រោង ឬកម្មវិធីជំនួយនានានៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំចុះអនុស្ស រណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិដោយភ្ជាប់ជាមួយ នូវសំណុំលិខិតដូចខាង ក្រោម :<br>- លិខិតរបស់ប្រធានអង្គការមិនមែនរដ្ឋាភិបាល បរទេសដែលមានទីស្នាក់ ការអចិន្ត្រៃយ៍របស់ ខ្លួននៅបរទេស សុំបើកទីស្នាក់ការតំណាង ដោយបញ្ជាក់លម្អិតពីគោលបំណងនៃការបើកទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា មួយ (០១) ច្បាប់<br>- លិខិតរបស់ប្រធានអង្គការមិនមែនរដ្ឋាភិបាល នៅបរទេស ដោយមានភ្ជាប់មកជាមួយនូវ ប្រវត្តិរូបសង្ខេបរបស់បុគ្គលដែលស្នើតែងតាំង ជាតំណាងរបស់អង្គការ ប្រចាំព្រះរាជាណា ចក្រកម្ពុជាមួយ (០១) ច្បាប់ | -កែទៅជាពាក្យ " ថវិកាដែលប៉ាន់ស្មាន"។<br>-ស្នើឱ្យមានអនុក្រឹត្យដែលចេញដោយក្រសួង និងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ដែលត្រូវចេញ លិខិតគាំទ្រ គម្រោង ឬកម្មវិធីក្នុងរយៈពេល ១០ថ្ងៃបន្ទាប់ពីបាន ទទួលការស្នើសុំ ។<br>- ប្តូរលក្ខខណ្ឌនេះទៅជាលិខិតប្រកាស ពីមូលនិធិ ដែលថាអង្គការនឹងដាក់តម្កល់ប្រាក់នៅធនាគារដែលមានការទទួល ស្គាល់ក្នុងរយៈពេល ៣០ថ្ងៃនៃការចុះបញ្ជី។<br>- លុបបំបាត់បញ្ញត្តិនេះ ប៉ុន្តែប្រសិនបើចាំបាច់ លក្ខខណ្ឌ នេះត្រូវកែតម្រូវដោយអនុវត្តចំពោះតែករណីផ្លាស់ប្តូរថ្នាក់ដឹកនាំ ឬអ្នកធ្វើការសម្រេចចិត្តសំខាន់ៗផ្សេងទៀត។ |

| | |
|---|---|
| - លិខិតប្រកាសថវិកាដែលសមមូលសម្រាប់ អនុវត្តគម្រោង ឬកម្មវិធីជំនួយនានារបស់អង្គការមិនមែនរដ្ឋាភិបាលបរទេសយ៉ាងតិច ក្នុងរយៈពេលមួយ (០១) ឆ្នាំ មួយ (០១) ច្បាប់<br>- ច្បាប់អនុញ្ញាតឱ្យដំណើរការអង្គការចេញដោយអាជ្ញាធរទទួលខុសត្រូវនៃប្រទេសដើមដែលជា ទីស្នាក់ការអចិន្ត្រៃយ៍របស់អង្គការនោះមួយ (០១) ច្បាប់<br>- លិខិតប្រកាសមូលនិធិដែលបានផ្ញើនៅធនាគារណាមួយដែលទទួលស្គាល់ដោយធនាគារជាតិ នៃកម្ពុជាសម្រាប់អនុវត្តគម្រោង ឬកម្មវិធី ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេសមួយ (០១) ច្បាប់<br>- លិខិតគាំទ្រគម្រោង ឬកម្មវិធីជំនួយនានារបស់ អង្គការមិនមែនរដ្ឋាភិបាលបរទេសចេញដោយ ក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាលមួយ ឬច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជាមួយ (០១) ច្បាប់<br>- បញ្ជីឈ្មោះបុគ្គលិកបរទេស និងបុគ្គលិកខ្មែរ ដែលត្រូវបម្រើការងារនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា មួយ (០១) ច្បាប់ ។ | |
| **មាត្រា ៣២.-ការពិនិត្យខ្លឹមសារសំណុំលិខិត និងការ ឆ្លើយតប**<br>ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិត្រូវពិនិត្យខ្លឹមសារនៃសំណុំលិខិត ហើយត្រូវ សម្រេចយល់ព្រម ឬមិនយល់ព្រមចុះអនុស្សរណៈ ជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេស ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ (៤៥) ថ្ងៃនៃថ្ងៃ ធ្វើការ ។ | អនុសាសន៍ដូចមាត្រា ១៧ |

| | |
|---|---|
| **មាត្រា ៤៦.-របាយការណ៍ប្រចាំឆ្នាំរបស់សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬសម្ព័ន្ធសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**<br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬ សម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលស្របច្បាប់ ត្រូវធ្វើរបាយការណ៍ស្តីពីសកម្មភាព និងស្ថានភាពថវិកាប្រចាំឆ្នាំកន្លងមក និងផែនការ សកម្មភាពសម្រាប់ឆ្នាំ បន្ទាប់ដើម្បីតម្កល់ទុកនៅ ទីស្នាក់ការរបស់ខ្លួន និងផ្ញើជូនក្រសួងមហាផ្ទៃ ឬ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ មិនឱ្យហួសពីដំណាច់ខែមករា។ | -ស្នើឱ្យមានការប្តូរកាលបរិច្ឆេទទៅដំណាច់ខែមីនា មិនមែនខែមករាទេ។<br>-កែមាត្រានេះដើម្បីបញ្ជាក់អំពីកាតព្វកិច្ចរបាយការណ៍ របស់សមាគម /អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និង សម្ព័ន្ធ សមាគម ដោយពិចារណាលើលក្ខខណ្ឌរបាយការណ៍ បញ្ចប់ដែលត្រូវលើកលែងចំពោះអង្គការតូចៗ ដោយ មិនបាច់ឱ្យរាយការណ៍ ឬ យ៉ាងហោចណាស់ធ្វើឱ្យ របាយការណ៍ មានលក្ខណៈសាមញ្ញ។ |
| **មាត្រា ៤៨.-សមត្ថកិច្ចត្រួតពិនិត្យរបាយការណ៍ ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការ មិនមែន រដ្ឋាភិបាល ឬសម្ព័ន្ធសមាគម ឬអង្គការមិន មែនរដ្ឋា ភិបាលក្នុងស្រុក**<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរ សវនកម្មជាតិមានសិទ្ធិត្រួតពិនិត្យរបាយការណ៍ស្តីពី ស្ថានភាពហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬសម្ពន្ឋ័សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ។ | - កែមាត្រានេះដោយបញ្ចូលនីតិវិធីការពារពារ ដូចជា ការជូនដំណឹងដូចជាពីរសប្តាហ៍ជាមុន អំពីការត្រួតពិនិត្យ និងលក្ខខណ្ឌដែលត្រូវធ្វើការត្រួតពិនិត្យ ក្នុងម៉ោង ធ្វើការ។<br>-គួរត្រូវធ្វើឡើងដោយសវនាករឯករាជ្យ។ |
| **មាត្រា ៤៩.-ការផ្អាកសកម្មភាព ឬការរំលោយ របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក**<br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុង ស្រុក ឬសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកអាចផ្អាកសកម្មភាព ឬរំលាយបានតាម ការកំណត់ក្នុងលក្ខន្តិកៈរបស់ខ្លួនដោយត្រូវជូនដំណឹង ជាលាយលក្ខណ៏អក្សរទៅក្រសួងមហាផ្ទៃ ។<br>ក្នុងករណីសមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក ឬសម្ព័ន្ធសមាគមនី | -ស្នើយោងលើមាត្រា ៦៤-៦៥ នៃក្រមរដ្ឋប្បវេណី ដើម្បីធ្វើជាមូលដ្ឋាននៃការរំលាយអង្គការ។<br>-កំណត់លក្ខណៈវិនិច្ឆ័យដើម្បីវាយតម្លៃអំពីការផ្អាក ឬការរំលាយ ។<br>-ផ្តល់ឱកាសឱ្យមានការប្តឹងឧទ្ធរណ៏ |

| | |
|---|---|
| ឬអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុកដែលសាលក្រម ឬសាល ដីកាស្ថាពររបស់តុលាការសម្រេចឱ្យផ្អាកសកម្មភាព ឬរំលាយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តតាម សេចក្ដីសម្រេចនេះ។ | |
| **មាត្រា ៥០.-ការផ្អាកសកម្មភាព ឬការបញ្ចប់សុពល ភាពអនុស្សរណៈរបស់អង្គការ មិនមែនរដ្ឋាភិបាល បរទេស**<br>អង្គការមិនមែនរដ្ឋាភិបាលបរទេសអាចស្នើសុំផ្អាកសកម្មភាព ឬសុំបញ្ចប់សុពលភាពអនុស្សរណៈបាន ដោយដាក់សំណើទៅក្រសួងការ បរទេស និងសហប្រតិបត្តិការអន្តរជាតិ និងចម្លងជូន ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។<br>ក្នុងករណីអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលសាលក្រមឬសាលដីការបស់តុលាការសម្រេចឱ្យផ្អាកសកម្មភាព ឬបញ្ចប់សុពលភាពអនុស្សរណៈ ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តតាមសេចក្ដី សម្រេចនេះ។ | អនុសាសន៍ដូចគ្នាមាត្រា ៤៩ |
| **មាត្រា ៥២.-ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ នៅពេលត្រូវរំលាយ ឬបញ្ចប់សុពលភាពអនុស្សរណៈ តាមសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ**<br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលត្រូវបានរំលាយ ឬបញ្ចប់សុពលភាព អនុស្សរណៈតាមសាលក្រម ឬសាលដីកាស្ថាពរ របស់តុលាការដែលបង្គាប់ឱ្យរំលាយ ឬបញ្ចប់សុពល ភាពអនុស្សរណៈការចាត់ចែងធនធាន និងទ្រព្យ សម្បត្តិត្រូវអនុវត្តតាមសាលក្រម ឬសាលដីកាស្ថាពរ របស់តុលាការ។ | -គ្រប់ករណីនៃការរំលាយអង្គការ ការចាត់ចែងទ្រព្យសម្បត្តិគួរតែត្រូវគ្រប់គ្រងដោយ លក្ខខន្តិកៈរបស់អង្គការ និងគោលការណ៍ណែនាំរបស់ម្ចាស់ជំនួយ។ |
| **មាត្រា ៥៣.-ការប្រព្រឹត្តល្មើសនឹងមាត្រា ៤៦**<br>ក្នុងករណីដែលសមាគម ឬអង្គការមិនមែន រដ្ឋាភិបាល ឬសម្ព័ន្ធសមាគម ឬ | -ទោសសម្រាប់អង្គការមិនមែនរដ្ឋាភិបាលបរទេស គួរ តែកាត់បន្ថយឱ្យស្រាលជាងទោសដែលអនុវត្តចំពោះអង្គការ មិនមែនរដ្ឋាភិបាល |

| | |
|---|---|
| អង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុកដែលស្របច្បាប់ មិនបានអនុវត្ត តាមមាត្រា ៤៦ នៃ ច្បាប់នេះក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើការ ព្រមានជាលាយលក្ខណ៏អក្សរ ។<br>ក្នុងករណីដែលសមាគម ឬអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក ឬសម្ព័ន្ធសមាគមនី ឬអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុកមិនរាងចាល ក្រសួងមហា ផ្ទៃ ត្រូវចេញសេចក្ដីសម្រេចជាលាយលក្ខណ៏អក្សរ ផ្អាកសកម្មភាពជាបណ្ដោះអាសន្នក្នុងរយៈពេលពីមួយ (០១) ទៅបី (០៣) ខែ ។<br>ក្នុងករណីដែលអង្គការមិនមែនរដ្ឋាភិបាល បរទេស មិនរាងចាល ក្រសួងការបរទេស និងសហ ប្រតិបត្តិការអន្តរជាតិត្រូវចេញសម្រេចជាលាយលក្ខណ៏អក្សរផ្អាកសកម្មភាព និង បញ្ចប់សុពលភាព អនុស្សរណៈ ។ | ក្នុងស្រុក។ |
| **មាត្រា ៩៤.-ការប្រព្រឹត្តល្មើសនឹងលក្ខន្តិកៈ ឬអនុស្ស រណៈ**<br>ក្នុងករណីដែលមានសមាគម ឬអង្គការ មិនមែនរដ្ឋាភិបាល ឬសម្ព័ន្ធសមាគម ឬអង្គការមិន មែនរដ្ឋាភិបាលក្នុងស្រុកដែលស្របច្បាប់ណា បាន អនុវត្តមិនត្រឹមត្រូវតាមលក្ខន្តិកៈ ឬអនុស្សរណៈ ក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និងសហ ប្រតិបត្តិការអន្តរជាតិត្រូវធ្វើការព្រមានជាលាយ លក្ខណ៏អក្សរទៅសមាគម ឬអង្គការមិនមែន រដ្ឋាភិបាល ឬសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋា ភិបាលក្នុងស្រុកនោះ ។<br>ក្នុងករណីមិនរាងចាល ឬករណីធ្ងន់ធ្ងរ ត្រូវ ផ្តន្ទាទោសតាមច្បាប់ជាធរមាន។ | - លុបចោល ពាក្យថា " ករណីធ្ងន់ធ្ងរ" ។<br>- គួរតែពិចារណាទោសជំនួសទោសព្រហ្មទណ្ឌ ដូចជា ការលុបចោល ការចុះបញ្ជី និង ការពិន័យ ។ |
| **មាត្រា ៩៥.-ការចុះបញ្ជីឡើងវិញរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬសម្ព័ន្ធ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក** | -ត្រូវរាប់បញ្ចូលនូវលក្ខខណ្ឌដែលរដ្ឋាភិបាលត្រូវ ជូនដំណឹងទៅសមាគម អង្គការមិនមែនរដ្ឋាភិបាល និង សម្ព័ន្ធ |

| | |
|---|---|
| បន្ទាប់ពីច្បាប់នេះចូលជាធរមានសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬសម្ព័ន្ធសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានតម្កល់សំណុំលិខិតនៅតាមស្ថាប័នរដ្ឋនានា ត្រូវរៀបចំសំណុំ លិខិតសុំចុះបញ្ជីសាជាថ្មីឡើងវិញ ស្របតាមការ កំណត់ដូចមានចែងក្នុងជំពូកទី ២ និងជំពូកទី ៣ នៃច្បាប់នេះរយៈពេលយ៉ាងយូរមួយរយប៉ែតសិប (១៨០) ថ្ងៃ ។ បើហួសរយៈពេលដូចបានកំណត់ខាងលើនេះត្រូវចាត់ទុកថាជាមោឃៈ ។ | អង្គការដែលចុះបញ្ជីអំពីកាតព្វកិច្ចនៃការ ដាក់ពាក្យសុំឡើង វិញ ។<br>-ចែងអំពីមូលដ្ឋានសម្រាប់ឱ្យក្រសួងមហាផ្ទៃ ធ្វើការ បដិសេធការ ដាក់ពាក្យសុំសាជាថ្មី ។<br>-កំណត់ពេលវេលាដែល ក្រសួងមហាផ្ទៃសម្រេច អំពីការចុះបញ្ជីសាជាថ្មី រយៈពេល ៤៥ថ្ងៃ-គ្រាន់តែជារយៈ ពេលសម្រាប់ត្រួតពិនិត្យពាក្យសុំចុះបញ្ជីជាលើកដំបូង ។ |
| **បញ្ហាពាក្យពេចន៍មិនច្បាស់លាស់នៅក្នុងច្បាប់** | បញ្ចូល សន្ទានុក្រមនៅផ្នែក ខាងក្រោយនៃច្បាប់ស្តីអំពីអង្គការ មិនមែនរដ្ឋាភិបាល ព្រមទាំងកំណត់ហេតុពន្យល់ នៅគ្រប់មាត្រា |

---

[i] ព្រះរាជាណាចក្រកម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ ( ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ១៩៩២ និង ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៩២)

[ii] អង្គការ Good Earth Japan (GEJ), អង្គការNPO/NGO Hearts of Gold (HG), អង្គការJapan Mine Action Service (JMAS), អង្គការ Japan International Volunteer Center (JVC), អង្គការ People's Forum on Cambodia, Japan (PEFOC,J), អង្គការ PH - Japan Foundation (PHJ), អង្គការ Services for the Health in Asian & African Regions (SHARE), អង្គការ Shanti Volunteer Association (SVA)

[iii] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ ( អនុមតិដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០៣) និងផែនការសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការដែលអនុមតិរាជរដ្ឋាភិបាលនៅក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥

[iv] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ ( អនុមតិដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០០៣

[v] អង្គការ The International Center for Not-for-Profit Law (ICNL), យោបល់និងអនុសាសន៍លើសេចក្តីព្រាងច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០